# ការវិភាគ

## របស់ព្រះតេជព្រះគុណ ហុក-សាវណ្ណ

## ក្រោមប្រធានបទ សហជីពកម្មករកាត់ដេរកម្ពុជាមានសិទ្ធិធ្វើកូដកម្ម

www.hoksavann,com

ថ្ងៃទី១២ តុលា ២០១០



ក្នុងពេលថ្មីៗនេះប្រធានសហភាពការងារកម្ពុជា បានដឹកនាំកម្មកររោងចក្រកាត់ដេររាប់ម៉ឺននាក់ ធ្វើកូដកម្មទាមទារតម្លើងប្រាក់ខែ ពី៧០ដុល្លារទៅ៩០ដុល្លារ អស់រយៈកាល៤ថ្ងៃ។ កូដកម្មនេះបានត្រូវបញ្ឈប់ដោយការធានាពីក្រសួងការងារថា នឹងយកបញ្ហានេះទៅដោះស្រា--យ ។ ពេលប្រជុំការងារពុំបានលើកយកសំណើសុំតម្លើងប្រាក់ខែមកដោះស្រាយឡើយ ក្រសួងការងារបានសុំកុំឲ្យកម្មករធ្វើកូដកម្មតទៅទៀត ហើយសុំកុំឲ្យថៅកែរោងចក្រប្តឹងកម្មករ ឲ្យសងការខូចខាតក្នុងពេលធ្វើកូដកម្ម ។

សូមបញ្ជាក់ថា មុននឹងឈានទៅដល់ការធ្វើកូដកម្មនេះ ប្រធានសហភាពការងារកម្ពុជាបានទាមទារឲ្យតម្លើងប្រាក់ខែពី៧០ដុល្លារដល់៩០ដុល្លារអស់ពេលយ៉ាងយូរ ប៉ុន្តែមិនបានសំរេច ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនិងក្រសួងការងារបានសំរេចតម្លើងប្រាក់ខែតែ៦ដុល្លារប-ន្ថែមទៅលើប្រាក់ខែគោលរួមត្រូវជា៦១ដុល្លារ ។ សេចក្តីសំរេចនេះ កម្មករនៃរោងចក្រខ្លះពុំគោរព គឺពុំយល់ស្របតាម ។ មួយទៀត បន្ទាប់ពីកូដកម្មត្រូវបញ្ឈប់ ក្រុមហ៊ុនរោងចក្រចំនួន១៧បានដាក់ពាក្យប្តឹងទៅតុលាការ ថាពួកគេបានខាតបង់ប្រាក់ចំនួន១៥លានដុល្លារក្នុងអំឡុងកម្មករធ្វើកូដកម្មនេះ ហើយរោងចក្រចំនួន១៦បានបញ្ឈប់កម្មករចំនួន៦៩២នាក់ ឲ្យឈប់ធ្វើការ ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនិងក្រសួងការងារបានសំរេចតម្លើងប្រាក់ខែត្រឹមតែ៦ដុល្លារដល់សហជីពកម្មកររោងចក្រកាត់ដេរ ។ ការតម្លើងដ៏តិចតួចនេះ មិនស្របតាមតម្លៃទំនិញសព្វសារពើចេះតែឡើងថ្លៃ ហើយកម្មករនិងកម្មការិនីទទួលយកឬមិនសុខចិត្តទទួលយក នៅតែទាមទារឲ្យបានច្រើនជាងនេះ ជាសិទ្ធិរបស់សហជីពកម្មករ មិនត្រូវបង្ខិតបង្ខំត្រូវតែទទួលយកឡើយ ព្រោះសេចក្តីសំរេចនេះពុំមែនជាច្បាប់រដ្ឋធម្មនុញ្ញ ឬជាក្រិត្យឬអនុក្រិត្យដែលត្រូវអនុវត្តតាមឡើយ ។

ការធ្វើបាតុកម្មនិងកូដកម្ម ជាសិទ្ធិរបស់ប្រជាពលរដ្ឋខ្មែរទូទៅ ជាពិសេសសហជីពកម្មករ ដែលសិទ្ធិនេះបានចែងក្នុងរដ្ឋធម្មនុញ្ញ ។ ការធ្វើកូដកម្មនេះបានសុំច្បាប់ហើយមិនប្រើហឹង្សា គឺជាកូដកម្មគ្រាន់តែមិនចូលធ្វើការ នាំគ្នាឈរនៅមុខរោងចក្រដូច្នេះមិនត្រូវទទួលខុសត្រូវក្នុងការខាតបង់របស់រោងចក្រឡើយ ។ មូលហេតុដែលនាំឲ្យធ្វើកូដកម្មនេះ គឺបណ្តាលមកពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្រសួងការងារតំណាងរដ្ឋាភិបាល និងថៅកែក្រុមហ៊ុនចេះតែពន្យាពេល ពុំព្រមដោះស្រាយឲ្យប្រាក់ខែសមរម្យឲ្យមានជីវភាពរស់នៅបានផង ។ ការតម្លើង៦ដុល្លារ ហើយ៤ឆ្នាំទើបលើកឡើងនិយាយគ្នាម្តងទៀត ជាការបន្ថោកតម្លៃនិងមើលងាយកម្មករ ព្រោះក្នុងមួយឆ្នាំៗ ប្រាក់រៀលបានចុះតម្លៃនិងទំនិញចេះតែឡើងថ្លៃ តែប្រាក់ខែងាប់បែបនេះ អាចឲ្យជីវិតរស់នៅបានឬទេ ? គួរឲ្យអាណិតកម្មការិនីខ្មែរដែលសុទ្ធតែជាស្ត្រី ត្រូវគេបន្ទាបតម្លៃដូចទាសករបែបនេះ ។

ការចោទថាកូដកម្មនេះមកពីមានអ្នកញុះញង់ នេះជាល្បិចរបស់អ្នកកាន់របបផ្តាច់ការ ឬបំបាក់ស្មារតីប្រជាពលរដ្ឋខ្មែរ មិនឲ្យហ៊ានក្រោកឡើងប្រឆាំងនឹងអ្នករំលោភច្បាប់ និងអំពើពុករលួយ ។ តាមពិតកិច្ចការអ្វីក៏ដោយ តែងតែមានមេដឹកនាំជាតំ-ណាងក្រុម ។ នៅប្រទេសដែលកាន់របបប្រជាធិបតេយ្យពិតប្រាកដមិនក្លែងក្លាយ គេមិនដែលចោទអ្នកនេះអ្នកនោះញុះញង់ឡើយ ឲ្យតែប្រជាពលរដ្ឋនាំគ្នាធ្វើ គេយល់ថាប្រជាពលរដ្ឋស្របឆន្ទៈគ្នាហើយ ។ ការចោទនេះជាការមើលងាយប្រជាពលរដ្ឋ បំបាក់ស្មារតីប្រជាពលរដ្ឋ មិបឲ្យប្រឆាំងនឹងអ្នកប្រព្រឹត្តអាក្រក់ នេះជាចរិតរបស់អាជ្ញាធរខ្មែរ ។ ចំពោះប្រធានសហភាពការ-ងារកម្ពុជា តាមដំណឹងថា មុននឹងធ្វើកូដកម្មបានបញ្ជូនលិខិតឲ្យកម្មករណាសុទ្ធចិត្តធ្វើកូដកម្មឲ្យចុះឈ្មោះនិងចុះហត្ថលេខាផង ពុំមែនញុះញង់ឡើយ គឺធ្វើដោយស្ម័គ្រចិត្ត ។

ចំពោះតុលាការខ្មែរខ្វះការពិចារណា សុខចិត្តទទួលពាក្យថៅកែក្រុមហ៊ុន ដែលប្តឹងកម្មករធ្វើកូដកម្ម នាំឲ្យខ្លួនខាតបង់ជាច្រើនលានដុល្លារ ជាបណ្តឹងគ្មានសមហេតុផល ព្រោះការខាតបង់បែបណាក៏ដោយ ពុំមែនជាកំហុសអ្នកធ្វើកូដកម្មឡើយ នេះគ្រាន់តែជាការបញ្ចេញមតិស្របតាមច្បាប់ ចំពោះអ្វីមួយដែលខ្លួនមិនពេញចិត្ត មិនប្រើអំពើហឹង្សាដែលនាំឲ្យខាតបង់របស់ទាំងនោះឡើយ ។ ចំពោះថៅកែរោងចក្រខ្លះបានបណ្តេញកម្មករឲ្យឈប់ធ្វើការ ដោយសារការធ្វើកូដកម្ម នេះជាការរំ-លោភសិទ្ធិកម្មករ ។ យើងសូមគាំទ្រប្រមុខដឹកនាំរាជរដ្ឋាភិបាលដែលបានសម្របសម្រួលថា សូមតុលាការទាត់ចោលពាក្យបណ្តឹង និងសូមឲ្យកម្មករដែលត្រូវគេបណ្តេញ សូមឲ្យចូលធ្វើការវិញ ។៚

☆ ☆

☆